**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ២៤ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មការសម្របសម្រួល គម្រោងសាងសង់ស្ពានឆ្លងកាត់ព្រំដែន ស្ទឹងបត់-បានណាងអៀង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

**ប្រការ១..**

ត្រូវបានបង្កើតគណៈកម្មការសម្របសម្រួលគម្រោងសាងសង់ស្ពានឆ្លងកាត់ព្រំដែន ស្ទឹងបត់-បានណាងអៀង ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ស៊ុន ចាន់ថុល** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២- ឯកឧត្តម **សុខុម គគចន្ទមុនី** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |

| | | | |
|---|---|---|---|
| ៣- ឯកឧត្តម | **ហ៊ីង ថូរ៉ាក់ស៊ី** | រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤- ឯកឧត្តម | **ហ៊ាន សាហ៊ីប** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥- ឯកឧត្តម | **អ៊ុង ស៊ាន** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៦- ឯកឧត្តម | **ជូ យិនស៊ីម** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៧- ឯកឧត្តម | **ម៉ក់ ពេជ្ររិទ្ធ** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកកាំកុងត្រូល | សមាជិក |
| ៨- ឯកឧត្តម | **លេង ទី** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៩- ឯកឧត្តម | **យិត បុណ្ណា** | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១០- ឯកឧត្តម | **គី សុគាត់** | អគ្គនាយកនៃអគ្គនាយកដ្ឋានសាធារណការនៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១១- ឯកឧត្តម | **គុណា ញឹម** | អគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករ | សមាជិក |
| ១២- ឯកឧត្តម | **ទូ ចន្ទ្រារ្ម:** | អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស នៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៣- ឯកឧត្តម | **សួន បវរ** | អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ | សមាជិក |
| ១៤- លោក | **ឡាយ សៀងលី** | ប្រធាននាយកដ្ឋានបច្ចេកទេសនិងវាស់វែងនៃលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន | សមាជិក។ |

**ប្រការ២.-**

គណៈកម្មការនេះមានភារកិច្ចដូចតទៅ៖

- ដឹកនាំ និងតម្រង់ទិសនៃការអនុវត្តគម្រោង
- សហការ និងសម្របសម្រួលជាមួយភាគីថៃ ក្នុងដំណើរការនៃការអនុវត្តគម្រោង
- សហការ និងរៀបចំកិច្ចព្រមព្រៀងសាងសង់ផ្សេងៗដែលពាក់ព័ន្ធជាមួយភាគីថៃ
- រៀបចំគោលការណ៍គ្រប់គ្រង និងត្រួតពិនិត្យការអនុវត្តគម្រោង
- ណែនាំ និងដោះស្រាយបញ្ហាផ្សេងៗដែលកើតឡើងនៅក្នុងពេលអនុវត្តគម្រោង
- ធ្វើរបាយការណ៍ស្ដីពីលទ្ធផលការងារ ជូនប្រមុខរាជរដ្ឋាភិបាល តាមរយៈទីស្ដីការគណៈរដ្ឋមន្ត្រី។

**ប្រការ៣.-**

ប្រធានគណៈកម្មការមានសិទ្ធិអញ្ជើញសមាជិកឱ្យចូលរួមប្រជុំ និងមានសិទ្ធិអញ្ជើញមន្ត្រីបច្ចេកទេសពាក់ព័ន្ធនៃក្រសួងសាធារណការ និងដឹកជញ្ជូន ឬលើកសំណើ ដើម្បីអញ្ជើញមន្ត្រីនៃក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ ដើម្បីពិគ្រោះយោបល់តាមការចាំបាច់។

**ប្រការ៤.-**

គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

**ប្រការ៥.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តបន្ទាយមានជ័យ
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ